# ការទទួលខុសត្រូវរបស់បុគ្គលិកបង្គោល ក្នុងក្រុមហ៊ុនល្បែងបៀរ កាលីហ្វ័រនីញ៉ា

## គណៈកម្មាការគ្រប់គ្រងល្បែងភ្នាល់ រដ្ឋកាលីហ្វនីញ៉ា

ក្នុងក្រុមហ៊ុនល្បែងបៀរកាលីហ្វ័រនីញ៉ា បុគ្គលិកគោលមានការអនុវត្តក្រោមបទដ្ឋានខ្ពស់ជាងបុគ្គលិកទូទៅ ។ ជាការពិត បុគ្គលិកគោលត្រូវបានចាត់ទុកថាជាផ្នែកមួយនៃ មេភ្នាល់ (The house) និងតម្រូវអោយមានការការធ្វើរបាយការណ៍ពិសេស ។ បុគ្គលិកគោលទាំងអស់គឺតម្រូវអោយអនុវត្តតាមគោលការណ៍ គ្រប់គ្រងល្បែងភ្នាល់ និង បទបញ្ញាទាំងឡាយណាដែលចេញផ្សាយពី គណៈកម្មាការគ្រប់គ្រងល្បែងភ្នាល់ រដ្ឋកាលីហ្វនីញ៉ា និង ការិយាល័យគ្រប់គ្រងល្បែងភ្នាល់ ។
ឯកសារលម្អិតទាំងស្រុងសម្រាប់ការអនុវត្ត និង បទបញ្ញាអាចរកបាននៅលើ គេហទំព័ររបស់គណៈកម្មាការ ។

**<u>បុគ្គលិកដែលមានអជ្ញាប័ណ្ណ</u>**

បុគ្គលិកគោលត្រូវប្រាកដថា មានពាក់និងបង្ហាញស្លាកសម្គាល់ខ្លួន និងឥរិយាបថម៉ឺងម៉ាត់ក្នុងម៉ោងការងារ ។

**<u>បុគ្គលិកគោលដែលមានអជ្ញាប័ណ្ណបណ្តោះអាសន្ន</u>**

- បុគ្គលិកដែលកាន់ប័ណ្ណការងារ អាចចាប់ផ្តើមធ្វើការជាបុគ្គលិកគោលបណ្តោះអាសន្ន ប្រសិនបើ បែបបទបុគ្គលិកគោល បណ្តោះអាសន្ន បានប្រគល់ជូនក្នុងអំឡុងពេល ១០ ថ្ងៃនៃការទទួលអោយធ្វើការ និង បែបបទបុគ្គលិកគោលបឋម បានប្រគល់ចន្លោះ ៣០ ថ្ងៃ ។
- អជ្ញាប័ណ្ណបុគ្គលិកគោលបណ្តោះអាសន្ន អាចសម្រេចផ្តល់ឱ្យ ឬ ច្រានចោលក្នុងចន្លោះពេល ១៥ ថ្ងៃការងារ ។
- មានសុពលភាពរយៈពេល ២ ឆ្នាំ ខណៈដែលបែបបទរបស់បុគ្គលិកគោល នៅបន្តតាមដាន និងពិនិត្យមើល
- អនុវត្តតាមច្បាប់ 4 CCR §12354

**<u>បុគ្គលិកគោលដែលមានអជ្ញាប័ណ្ណ</u>**

- មុនពេលអនុវត្តការងារ បុគ្គលិកគោលតម្រូវអោយមានអជ្ញាប័ណ្ណដែលមានសុពលភាព លើកលែងពីរករណី ៖
    1. បុគ្គលិកដែលមិនទាន់បានបញ្ជូនបែបបទបុគ្គលិកគោលបណ្តោះអាសន្ន ក្នុងរយៈពេល ១០ ថ្ងៃ នៃការទទួលអោយធ្វើការ និង រង់ចាំការសម្រេច ។
    2. បុគ្គលិកដែលធ្វើការអោយ ក្រុមហ៊ុនសាជីវកម្ម អាចចាប់ផ្តើមធ្វើការបានជាបុគ្គលិកគោល ប្រសិនបើពួកគេបានបញ្ជូនបែបបទទៅកាន់ការិយាល័យ ក្នុងអំឡុងពេល ៣០ ថ្ងៃដោយសន្មតតាមតំណែងបុគ្គលិកគោល ។
- គណៈកម្មាការនឹងធ្វើចំណាត់ការលើបែបបទក្នុងអំឡុងពេល ១២០ថ្ងៃ បន្ទាប់ពីការិយាល័យបានបញ្ជូនបែបបទទៅកាន់គណៈកម្មាការ ។ ពេលវេលានៃការអនុវត្តអាចលើសពីនេះ ប្រសិនបើមានករណីចាំបាច់ ។
- អនុវត្តតាមច្បាប់ Business and Professions Code §§19883, 19855; 4 CCR §12350

<u>ារបន្តសុពលភាពអជ្ញាប័ណ្ណរបស់បុគ្គលិកគោល</u>

- អជ្ញាប័ណ្ណត្រូវតែបន្តសុពលភាពរាល់ ២ ឆ្នាំម្តង
- បំពេញ បែបបទបន្តសុពលភាព នៅការិយាល័យអំឡុង ១២០ថ្ងៃ ចន្លោះពេលដែលអជ្ញាប័ណ្ណបច្ចុប្បន្នអស់សុពលភាព ។
- វាជា **ទំនួលខុសត្រូវរបស់អ្នក** ក្នុងការបំពេញបែបបទឱ្យបានទាន់ពេលវេលាជាមួយការិយាល័យ ! កុំ ពឹងផ្អែកលើ ភ្នាក់ងារនានា ឬ ភាគីទីបី ដើម្បីធានាភាពជាក់លាក់ ការបញ្ចប់រួចរាល់ និង ទាន់ពេលវេលានៃបែបបទឯកសារបន្តសុពលភាព ។

# ការទទួលខុសត្រូវរបស់បុគ្គលិកគោលក្នុងក្រុមហ៊ុនល្បែងបៀរ កាលីហ្វ័រនីញ៉ា

## ការរាយការណ៍

បុគ្គលិកគោលតម្រូវអោយមានការជូនដំណឹងជាលាយលក្ខអក្សរក្នុងករណីដូចខាងក្រោម ក្នុងអំឡុងពេល ៥ថ្ងៃ ៖

- អាចបានដឹង អំពីការបំពាន ការអនុវត្ត ឬ បទបញ្ញារបស់គណៈកម្មាការ
- បន្ទាប់ពីបានដឹង ជូនដំណឹង ឬ ទំនាក់ទំនងជាមួយ សមត្ថកិច្ចជំនាញផ្នែកច្បាប់ ក្នុងករណីមានការសង្ស័យ អំពីការបំពានការអនុវត្ត ឬ បទបញ្ញា និង កំណត់បញ្ជាក់ច្បាប់ជាក់លាក់ដែលបានបំពាន ។ អាចពិនិត្យមើលក្រម 4 CCR §12395(a)(3)(A) សម្រាប់បញ្ជីករណីបំពានជាក់លាក់ដែលគួររាយការណ៍
- រាល់ករណីរាយការណ៍ក្លែងបន្លំទាំងឡាយណា ពីអ្នកចុះបញ្ជី ឬ អ្នកកាន់អជ្ញាប័ណ្ណ ។
- តាមក្រម 11 CCR §2052(c); 4 CCR §§12395(a)(3)(A), 12200.7(17)

បុគ្គលិកគោលត្រូវតែជូនដំណឹងទៅកាន់ការិយាល័យជាលាយលក្ខអក្សរក្នុងករណីដូចខាងក្រោម ក្នុងអំឡុងពេល ១០ ថ្ងៃ៖

- ជម្លោះផ្លូវច្បាប់ទាំងឡាយណា រវាងម្ចាស់កម្មសិទ្ធិបឋមរបស់ក្រុមហ៊ុន ភ្នាក់ងារសេវាល្បែងភ្នាល់ទីបី (TPPPS) ជាមួយមេភ្នាល់ ឬ បុគ្គលិកគោល ។
- ការចាប់ខ្លួន អ្នកចុះបញ្ជីភ្នាក់ងារសេវាល្បែងភ្នាល់ទីបី (TPPPS) ចំពោះការបើកល្បែងភ្នាល់ ។
- ការដកហូតការចុះបញ្ជីពី ភ្នាក់ងារសេវាល្បែងភ្នាល់ទីបី (TPPPS) តាមការអនុវត្តរបស់នគរបាលសមត្ថកិច្ច ឬ មេភ្នាល់
- ជម្លោះរវាង ភ្នាក់ងារសេវាល្បែងភ្នាល់ទីបី (TPPPS) និង អ្នកភ្នាល់ល្បែង ដែលឈានដល់ការធ្វើរបាយការណ៍ពី នគរបាលសមត្ថកិច្ច និង ដកហូតការចុះបញ្ជី ។
- អនុវត្តតាមច្បាប់ 4 CCR §12200.7(16); Business and Professions Code §19805(t)

## ការដោះដូរបុគ្គលិក

- ត្រូវជូនដំណឹងទៅកាន់ការិយាល័យក្នុងអំឡុងពេល ១០ ថ្ងៃនៃការទទួល ឬ បញ្ឈប់បុគ្គលិកក្នុងក្រុមហ៊ុនល្បែងបៀរ ។
- ត្រូវចងចាំថា អជ្ញាប័ណ្ណបុគ្គលិកគោលគឺជារបស់បុគ្គល អជ្ញាប័ណ្ណរបស់អ្នកត្រូវនៅជាប់ជាមួយអ្នក មិនមែនជារបស់ ក្រុមហ៊ុនល្បែងបៀរទេ ដូច្នេះត្រូវជូនដំណឹងរាល់ការផ្លាស់ប្តូរកន្លែងការងារ ។
- អនុវត្តតាមច្បាប់ 4 CCR §12352(a); Business and Professions Code §19854(c)(2)

## បុគ្គលិកគោលក្នុងភារកិច្ច

- យ៉ាងតិចណាស់ត្រូវមានបុគ្គលិកគោលដែលមានអជ្ញាប័ណ្ណ ម្នាក់ ក្នុងម៉ោងដំណើរល្បែងភ្នាល់ ដើម្បីធ្វើការត្រួតពិនិត្យ និង ធានាការប្រព្រឹត្តិទៅ តាមការអនុវត្ត និង បទបញ្ញារបស់គណៈកម្មាការគ្រប់គ្រងល្បែងភ្នាល់ ។
- អនុវត្តតាមច្បាប់ 11 CCR §2050 និង 4 CCR §12391(b)

## វគ្គបណ្តុះបណ្តាលលើការដោះស្រាយបញ្ហាល្បែងភ្នាល់

- បុគ្គលិកគោលតម្រូវអោយទទួលការបណ្តុះបណ្តាលលើការដោះស្រាយបញ្ហាល្បែងភ្នាល់ ជារៀងរាល់ឆ្នាំ
- បុគ្គលិកថ្មី ត្រូវទទួលការបណ្តុះបណ្តាលការដោះស្រាយបញ្ហាល្បែងភ្នាល់ ក្នុងអំឡុងពេល ៦០ ថ្ងៃ បន្ទាប់ពីទទួលបានអជ្ញាប័ណ្ណ ឬ ចាប់ផ្តើមការងារ អាស្រ័យតាមករណី ណាមួយកើតឡើងមុន ។
- អនុវត្តតាមច្បាប់ 4 CCR §12462 (b)(1) & (c)(3)

# ការទទួលខុសត្រូវរបស់បុគ្គលិកបង្គោលក្នុងក្រុមហ៊ុនល្បែងបៀរ កាលីហ្វ័រនីញ៉ា

## ការមិនទទួល ឬ ការដាក់កម្រិត អ្នកភ្នាល់ល្បែង

- ត្រូវអនុវត្តសកម្មភាពសមស្រប ដើម្បីបដិសេធមិនទទួលអ្នកភ្នាល់ល្បែង ដោយប្រកាសទូទាំងរដ្ឋទាំងមូល និងដាក់បញ្ចូលឈ្មោះទៅកាន់បញ្ជីហាមឃាត់ សម្រាប់ការមិនទទួល ឬ ការដាក់កម្រិតអ្នកភ្នាល់ល្បែង ។
- ជូនដំណឹងទៅកាន់ការិយាល័យ ចំពោះបុគ្គលអ្នកភ្នាល់ល្បែងមានឈ្មោះក្នុងបញ្ជីហាមឃាត់ ដែលបានចូលលេងភ្នាល់ ឬ ព្យាយាមចូលភ្នាល់ ។
- អនុវត្តតាមច្បាប់ 4 CCR §§12362(q), 12463, 12464

## ការហាមឃាត់

បុគ្គលិកគោលត្រូវបានហាមឃាត់ចំពោះ ៖

- ធ្វើជាអ្នកលេងភ្នាល់ ក្នុងក្រុមហ៊ុនដែលពួកគេធ្វើការ
- ទទួលនូវភាគលាភ ពីការភ្នាល់ល្បែង ទោះបីចាញ់ ឬ ឈ្នះ ក្នុងក្រុមហ៊ុនដែលពួកគេធ្វើការ
- ធ្វើការតបតប្រឆាំងអ្នកដទៃដែលបានទំនាក់ទំនងរាយការណ៍ជូន គណៈកម្មការ ការិយាល័យ ឬ ភ្នាក់ងារដទៃ
- ធ្វើការណែនាំសេវាភ្នាល់ដល់អ្នកលេងល្បែងភ្នាល់ ក្នុងពេលកាន់ភារកិច្ចជា បុគ្គលិកគោល ក្នុងល្បែងភ្នាល់
- អនុវត្តតាមច្បាប់ Business and Professions Code §§19805(c), 19805(t), 19984(a); Penal Code 330.11; 4 CCR §12200.7(b)(11), (d) & (e)